ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តស្ទឹងត្រែង

សំណុំរឿងលេខៈ ១៦
ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២១
សាលក្រមលេខៈ ៥៨ "គ"
ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០២១

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តស្ទឹងត្រែង

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ
ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០២១

**ចៅក្រមទទួលបន្ទុក**

**លោក** [redacted] **ចៅក្រមសាលាដំបូងខេត្តស្ទឹងត្រែង**

**ក្រឡាបញ្ជី**

**លោក** [redacted] **ក្រឡាបញ្ជីសាលាដំបូងខេត្តស្ទឹងត្រែង**

**ដើមចោទៈ** ឈ្មោះ [redacted] **យិន** ភេទប្រុស អាយុ ៣៤ ឆ្នាំ មុខរបរ កសិករ។
អាសយដ្ឋានៈ [redacted]។

**អ្នកតំណាងដោយអាណត្តិៈ** លោក [redacted] មេធាវីតំណាងដោយអាណត្តិ មានអាសយដ្ឋាន [redacted]។

**ចុងចម្លើយៈ** ឈ្មោះ [redacted] **អិត** ភេទស្រី អាយុ ៤៩ ឆ្នាំ មុខរបរ កសិករ។
អាសយដ្ឋានៈ [redacted]។

**អ្នកតំណាងដោយអាណត្តិៈ** លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ មានអាសយដ្ឋាន [redacted]។

## អង្គហេតុ និងចំណុចវិវាទ

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

១-សុំបែងចែកទ្រព្យសម្បត្តិរួម ជាពីរចំណែកស្មើគ្នាមានដូចជាៈ

១.១-ដីចំការទំហំ ២៤៥០៧ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅ [redacted] មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៧០១-១០៥៣ ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០១៤ ។

១.២-ដីចំការទំហំ ២,៥ហិចតា មានទីតាំងស្ថិតនៅ [redacted] មានពាក្យសុំកាន់កាប់លេខ ១៤៦/១៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៣។

២-សុំសិទ្ធិចាត់ចែងម៉ូតូចំនួន ១គ្រឿង ម៉ាកវេវអាល់ហ្វា និងប្រគល់ម៉ូតូម៉ាក ហុងដាឌ្រីម ផលិតឆ្នាំ២០១៦ ចំនួន ១គ្រឿង ឱ្យទៅចុងចម្លើយឈ្មោះ [redacted] **អិត** ជាអ្នកមានសិទ្ធិចាត់ចែង។

៣-ឱ្យខ្ញុំ និងចុងចម្លើយឈ្មោះ [redacted] **អិត** ជាអ្នកសងប្រាក់ជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួនពាក់កណ្ដាល ក្នុងម្នាក់ៗ នៃបំណុលរួមចំនួន ៣២.០០០.០០០ រៀល។



Scanned with CamScanner

## ខ. ដំណើររឿងក្ដី និងចំណុចវិវាទ

### ខ.១ ការសង្ខេបអំពីរឿងក្ដី

កាលពីអំឡុងឆ្នាំ ២០០៩ ដើមចោទឈ្មោះ [redacted] **ឃិន** និងចុងចម្លើយឈ្មោះ [redacted] **អិត** បានរៀបអាពាហ៍ពិពាហ៍នឹងគ្នា តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ។ ការរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធគឺមិនចុះសម្រុងនឹងគ្នានោះទេ ដែលនាំឲ្យដើមចោទ និងចម្លើយចុងចម្លើយដាក់ពាក្យបណ្ដឹងមកតុលាការធ្វើការបែងចែកនូវទ្រព្យសម្បត្តិរួមៈ ដីចំការមានទំហំ ២៤៥០៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៧០១-១០៥៣ ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០១៤ ដីចំការទំហំ ២,៥ហិចតា មានទីតាំងស្ថិតនៅភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានពាក្យសុំកាន់កាប់លេខ ១៤៦/១៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៣ ម៉ូតូចំនួន២គ្រឿង ម៉ាកវេវអាល់ហ្វា និងម៉ាកហុងដាឌ្រីមផលិតឆ្នាំ២០១៦ និងបំណុលរួមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួន ៣២.០០០.០០០ រៀល។

### ខ.២ អង្គហេតុគ្មានវិវាទ

-ចុងចម្លើយយល់ព្រមតាមការទាមទាររបស់ដើមចោទ ចំពោះការប្រគល់ម៉ូតូចំនួន១គ្រឿង ម៉ាកវេវអាល់ហ្វា ឱ្យទៅដើមចោទ និងចុងចម្លើយទទួលយកម៉ូតូម៉ាក ហុងដាឌ្រីម ផលិតឆ្នាំ ២០១៦ ចំនួន១គ្រឿង។

-ចុងចម្លើយយល់ព្រមទទួលសងបំណុលជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួន ៣២.០០០.០០០ រៀល តែម្នាក់ឯង។

### ខ.៣ អង្គហេតុវិវាទ

-ដីចំការមានទំហំ ២៤៥០៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៧០១-១០៥៣ ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០១៤ ជាទ្រព្យសម្បត្តិរួមរបស់ភាគី មែនដែរ ឬទេ?

-ដីចំការទំហំ ២,៥ហិចតា មានទីតាំងស្ថិតនៅភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានពាក្យសុំកាន់កាប់លេខ ១៤៦/១៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៣ និងដីចំការមានទំហំ ២៤៥០៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៧០១-១០៥៣ ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០១៤ ជាដីតែមួយ មែនដែរ ឬទេ?

### ខ.៤ ការអះអាងរបស់ភាគីស្ដីពីចំណុចវិវាទ

**-ចំណុចវិវាទទី១**

**ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ**

ដើមចោទ និងចុងចម្លើយឈ្មោះ [redacted] **អិត** ពិតជាបានរៀបការនឹងគ្នាពិតមែន តែមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍។ ដីចំការទំហំ ២៤៥០៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៧០១-១០៥៣ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៤ ជាទ្រព្យសម្បត្តិរួម ដែលដើមចោទ និងចុងចម្លើយបង្កើតរួមគ្នា ពេលរស់នៅជាប្ដីប្រពន្ធនឹងគ្នា។

**ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ**

ដីចំការទំហំ ២៤៥០៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៧០១-១០៥៣ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៤ មិនមែនជាទ្រព្យសម្បត្តិរួម គឺទ្រព្យសម្បត្តិដែលចុងចម្លើយទទួលបានពីបងស្រីរបស់ខ្លួនឈ្មោះ [redacted] **សំអុល** ហើយនៅពេលមន្ត្រីមានសមត្ថកិច្ចទៅធ្វើការចុះបញ្ជី គេបានសួរចុងចម្លើយថាមានប្ដីឬអត់ ទើបចុងចម្លើយប្រាប់ថាមានដើមចោទជាប្ដី ដូច្នេះមន្ត្រីក៏ចុះបញ្ជីថា ជាទ្រព្យរួមប្ដីប្រពន្ធ តែម្ដងទៅ។ ក្នុងអង្គហេតុនេះចុងចម្លើយមានភស្តុតាងបញ្ជាក់ដូចជា៖

-ឈ្មោះ [redacted] **សំអុល** ជាអ្នកផ្ដល់ដីដំបូងមកឱ្យមកចុងចម្លើយ។

-ឈ្មោះ [redacted] ជានី និងឈ្មោះ [redacted] ហុង ជាអ្នកជិតខាងដែលបានដឹងថាឈ្មោះ [redacted] សំអុល បានប្រគល់ដីមកឱ្យចុងចម្លើយ មុនពេលដែលចុងចម្លើយបានយកដើមចោទជាប្តីប្រពន្ធ។

-លិខិតបញ្ជាក់លេខ ៨៧៩/២១ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២១ របស់មេឃុំស្រែក្រសាំង ដែលបញ្ជាក់ថា ដីនេះដំបូងឡើយជាដីរបស់ឈ្មោះ [redacted] ភើយ និងប្រពន្ធឈ្មោះ [redacted] សំអុល បានប្រគល់ឱ្យចុងចម្លើយតែម្នាក់។

**-ចំណុចវិវាទទី២**

**ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ**

ដីចំការទំហំ ២,៥ហិចតា មានទីតាំងស្ថិតនៅភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានពាក្យសុំកាន់កាប់លេខ ១៤៦/១៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៣ ក៏ជាទ្រព្យសម្បត្តិរួម ដែលដើមចោទ និងចុងចម្លើយបង្កើតរួមគ្នា ពេលរស់នៅជាប្តីប្រពន្ធនឹងគ្នា។

**ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ**

ដីចំការទំហំ ២,៥ហិចតា មានទីតាំងស្ថិតនៅភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានពាក្យសុំកាន់កាប់លេខ ១៤៦/១៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៣ និងដីចំការទំហំ ២៤៥០៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៧០១-១០៥៣ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៤ ជាដីតែមួយ ដោយនៅដំបូងឡើយនៅមុនពេលមិនទាន់ចុះបញ្ជីគឺដីនោះមានពាក្យសុំកាន់កាប់លេខ ១៤៦/១៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៣ ហើយក្រោយពេលចុះបញ្ជីដីនោះមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៧០១-១០៥៣ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៤។ ក្នុងអង្គហេតុនេះចុងចម្លើយមានភស្តុតាងបញ្ជាក់ដូចជា៖ ឈ្មោះ [redacted] សំអុល ឈ្មោះ [redacted] ជានី និងឈ្មោះ [redacted] ហុង ដែលអាចបញ្ជាក់ដីដែលដើមចោទទាមទារបែងចែកគឺជាដីតែមួយ។ ម្យ៉ាងទៀត លិខិតបញ្ជាក់លេខ ៨៧៩/២១ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២១ របស់មេឃុំស្រែក្រសាំង ក៏អាចបញ្ជាក់ថា ដីទាំងពីរកន្លែងដែលដើមចោទបានធ្វើការទាមទារ តាមពិតជាដីតែមួយ។

## សំអាងហេតុ

### ក.ស្តីពីចំណុចវិវាទទី១

តាមការអះអាងរបស់ចុងចម្លើយឈ្មោះ [redacted] អិត ឈ្មោះ [redacted] សំអុល ឈ្មោះ [redacted] ជានី និងឈ្មោះ [redacted] ហុង និងលិខិតបញ្ជាក់លេខ ៨៧៩/២១ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២១ របស់មេឃុំស្រែក្រសាំង តុលាការទទួលស្គាល់ថា ដីចំការទំហំ ២៤៥០៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៧០១-១០៥៣ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៤ គឺជាដីដែលចុងចម្លើយឈ្មោះ [redacted] អិត ទទួលបានពីឈ្មោះ [redacted] សំអុល និងឈ្មោះ [redacted] ភើយ នៅមុនពេលដែលរួមរស់នៅជាមួយគ្នាជាអនីតិសង្វាសជាមួយដើមចោទ។ ដូច្នេះអាចកំណត់បានថានេះជាទ្រព្យសម្បត្តិដោឡែករបស់ចុងចម្លើយ។

### ខ.ស្តីពីចំណុចវិវាទទី២

តាមការអះអាងរបស់ចុងចម្លើយឈ្មោះ [redacted] អិត ឈ្មោះ [redacted] សំអុល ឈ្មោះ [redacted] ជានី និងឈ្មោះ [redacted] ហុង និងលិខិតបញ្ជាក់លេខ ៨៧៩/២១ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២១ របស់មេឃុំស្រែក្រសាំង តុលាការទទួលស្គាល់ថា ដីចំការទំហំ ២,៥ហិចតា មានទីតាំងស្ថិតនៅភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានពាក្យសុំកាន់កាប់លេខ ១៤៦/១៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៣ និងដីចំការទំហំ ២៤៥០៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៧០១-១០៥៣ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៤ ជាដីតែមួយ ដោយនៅមុនពេលមិនទាន់ចុះបញ្ជីគឺដីនេះ ប្រើពាក្យសុំកាន់កាប់លេខ ១៤៦/១៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៣ ហើយក្រោយពេលចុះបញ្ជីដីនេះប្រើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៧០១-១០៥៣ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៤ វិញ។



Scanned with CamScanner

**ខ. ការវិនិច្ឆ័យអំពីការទាមទារ**

-ចំពោះការទាមទារចំណុចទី១(១.១)៖ តុលាការបានរកឃើញថា ដីចំការទំហំ ២៤៥០៧ម៉ែត្រការ៉េ ស្ថិតនៅភូមិ ឃុំ ស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៧០១-១០៥៣ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៤ គឺជាទ្រព្យសម្បត្តដោយឡែករបស់ចុងចម្លើយ។ ដូច្នេះការទាមទាររបស់ដើមចោទត្រង់ ចំណុចនេះគឺត្រូវច្រានចោល។

-ចំពោះការទាមទារចំណុចទី១ (១.១)៖ តុលាការបានរកឃើញថាដីចំការទំហំ ២,៥ហិចតា មានទីតាំងស្ថិតនៅ ភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានពាក្យសុំកាន់កាប់លេខ ១៨៦/១៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៣ និងដីចំការទំហំ ២៤៥០៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្ត ស្ទឹងត្រែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៧០១-១០៥៣ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៤ ជាដីតែមួយ។ ដូច្នេះការទាមទាររបស់ដើមចោទត្រង់ ចំណុចនេះគឺត្រូវច្រានចោល។

-ចំពោះការទាមទារត្រង់ចំណុចទី២៖ ភាគីមិនមានវិវាទនឹងគ្នាទេ ដោយភាគីបានព្រមព្រៀងគ្នាថា ម៉ូតូចំនួន១ គ្រឿង ម៉ាកវ៉េវអាល់ហ្វា ត្រូវប្រគល់ឱ្យទៅ ដើមចោទ និងចុងចម្លើយទទួលយកម៉ូតូម៉ាក ហុងដាឌ្រីម ផលិតឆ្នាំ ២០១៦ ចំនួន១គ្រឿង។ ដូច្នេះ តុលាការនឹងសម្រេចតាមការចាត់ចែងរបស់ភាគី។

-ចំពោះការទាមទារចំណុចទី៣៖ ទោះបីចុងចម្លើយយល់ព្រមទទួលរ៉ាប់រងនូវបំណុលរួមដែលជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួន ៣២.០០០.០០០ រៀល តែម្នាក់ឯង ក៏តុលាការមិនអាចសម្រេចតាមបានដែរ ពីព្រោះ បំណុលនេះជាកាតព្វកិច្ចសាមគ្គីរបស់ដើមចោទ និងចុងចម្លើយ ហើយម្ចាស់បំណុលមានសិទ្ធិក្នុងការទាមទារឱ្យដើមចោទ ទទួលបន្ទុក ឬចុងចម្លើយទទួលបន្ទុក ឬទាំងដើមចោទ និងចុងចម្លើយទទួលបន្ទុកទាំងអស់គ្នា។ ដូច្នេះ ក្នុងករណីតុលាការ សម្រេចតាមការទាមទាររបស់ភាគីនឹងនាំឱ្យប៉ះពាល់ចំពោះសិទ្ធិរបស់ម្ចាស់បំណុល។ ដូច្នេះ ការទាមទារត្រង់ចំណុចនេះ ត្រូវច្រានចោល។

**គ. ស្ដីពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី**

ភាគីដើមចោទជាភាគីចាញ់ក្ដី ដូច្នេះដើមចោទត្រូវទទួលរ៉ាប់រងប្រាក់ប្រដាប់ក្ដីទាំងស្រុង។

**សេចក្ដីសម្រេចបញ្ចប់**

១-ម៉ូតូចំនួនមួយគ្រឿង ម៉ាកវ៉េវអាល់ហ្វា ត្រូវប្រគល់ឱ្យទៅដើមចោទឈ្មោះ [redacted] យិន ចំណែកឯ ម៉ូតូមួយគ្រឿង ម៉ាកហុងដាឌ្រីម ផលិតឆ្នាំ ២០១៦ ត្រូវប្រគល់ឱ្យចុងចម្លើយឈ្មោះ [redacted] អិត។

២-ការទាមទារក្រៅពីនេះរបស់ដើមចោទត្រូវច្រានចោល។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០២១។ ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍ ត្រូវធ្វើឡើងនៅក្នុងរយៈពេល ១ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃអង្គារ ៤រោច ខែកត្ដិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ខេត្តស្ទឹងត្រែង ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០២១

**ចៅក្រម**

**ហត្ថលេខា និងត្រា៖** [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃ អង្គារ ៤រោច ខែ កត្ដិក ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ខេត្តស្ទឹងត្រែង ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០២១

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]